ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៤៥/២០ - អេស អ៊ី ភី អាយ អេ (ខេមបូឌា)
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ឹង សុទ្ធី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លៈ

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន**
អាសយដ្ឋាន ៖ ភូមិត្រពាំងជ្រៃ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០១៦ ៤៥ ៩៧ ៥៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

- លោក គង់ សម្បត្តិ រដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន**
អាសយដ្ឋាន ៖ ភូមិត្រពាំងជ្រៃ សង្កាត់កាកាប២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ
ទូរស័ព្ទ ៖ ០៩២ ៣៩ ៣៦ ៣៧, ០១០ ៥០ ១៥ ៦៨ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ម៉ាំង មាស មន្ត្រីសហព័ន្ធCFWS
២- លោក ម៉ម ធរី មន្ត្រីសហព័ន្ធសហជីពសំឡេងកម្មករនិយោជិត
៣- លោក ខុំ អ៊ុន មន្ត្រីសហព័ន្ធសហជីពសេរីភាពកម្មករខ្មែរ
៤- លោកស្រី ប៉ែន ចាន់ណារី អនុប្រធានសហជីពសំឡេងកម្មករនិយោជិត
៥- លោកស្រី ហែម សេរីសោភា លេខាសហជីពសេរីភាពកម្មករខ្មែរ
៦- លោក ស៊ាន រតណា កម្មករនិយោជិត
៧- លោក សេង គឹមហាន កម្មករនិយោជិត

៨- លោក វឿន វ៉េត កម្មករនិយោជិត

៩- លោក សឿន សុខចាន់ កម្មករនិយោជិត

១០- លោកស្រី លឹម ប៉ារី កម្មករនិយោជិត

១១- លោកស្រី វឿន សារ៉ែ កម្មករនិយោជិត

១២- លោកស្រី ភួន សុខជា កម្មករនិយោជិត

១៣- លោកស្រី ជិន ពៅ កម្មករនិយោជិត

១៤- លោកស្រី ខុន ស្រីនាង កម្មករនិយោជិត

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបើកប្រាក់ឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់។

២- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនមានពេទ្យប្រចាំការក្នុងម៉ោងធ្វើការ និងមានសម្ភារៈពេទ្យគ្រប់គ្រាន់ ជូនកម្មករនិយោជិត។

៣- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់កិច្ចសន្យាការងារ ៥% ដែលក្រុមហ៊ុនមិនបានផ្តល់ជូនកម្មករនិយោជិត។

៤- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់លំហែមាតុភាព ៥០% ជូនបងប្អូនកម្មករនិយោជិតទាំងអស់ ដែលបានដាក់ច្បាប់ឈប់សម្រាកលំហែមាតុភាពដែលក្រុមហ៊ុនមិនទាន់ផ្តល់ជូន។

៥- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបង់ប្រាក់ភាគទានចូលបេឡាជាតិរបបសន្តិសុខសង្គមឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើប្រាស់សេវា ប.ស.ស តាមមន្ទីរពេទ្យនានាដែលជាដៃគូរបស់ ប.ស.ស។

៦- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបើកលុយបាយថែមម៉ោងមួយសប្តាហ៍ម្តង ឱ្យបានទៀងទាត់ និងលុយបាយដែលក្រុមហ៊ុនមិនទាន់បានផ្តល់ជូនកម្មករនិយោជិត។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន លេខ ៧៤៦ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។

## សវនាការ និង សង្ខេបនីតិវិធី

ទីកន្លែងសវនាការ ៖ ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

កាលបរិច្ឆេទសវនាការ ៖ ថ្ងៃពុធ ១រោច ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី០៥ ខែសីហា ឆ្នាំ២០២០។

បញ្ហានីតិវិធី ៖

នៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន ស្តីពីការទាមទារឱ្យក្រុមហ៊ុនដោះស្រាយលក្ខខណ្ឌការងារ ចំនួន ៧ចំណុច។ បន្ទាប់ពីទទួលពាក្យបណ្តឹងនេះមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីឱ្យផ្សះផ្សាវិវាទការងារនេះជាបន្តបន្ទាប់ និងផ្សះផ្សានៅថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា។ យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន លេខ ៧៤៦ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០ បានបញ្ជាក់ថា ចំណុចវិវាទទី៧ ពាក់ព័ន្ធទៅនឹងការព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត អ្នកផ្សះផ្សានឹងពិនិត្យបន្តតាមនីតិវិធី ដោយសម្រេចមិនបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាល ដើម្បីដោះស្រាយលើចំណុចនេះទេ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាល នឹងដោះស្រាយចំណុចវិវាទចំនួន ៦ចំណុច ដូចមាននៅក្នុងរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួម ដែលបញ្ជូនមកតែប៉ុណ្ណោះ។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៩ ខែកក្កដា ឆ្នាំ ២០២០។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិត មកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៦ចំណុចនេះ នៅថ្ងៃទី៥ ខែសីហា ឆ្នាំ២០២០ វេលាម៉ោង ២ រសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សា-អាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៦ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទបន្ថែមទៀត ដោយភាគីបានព្រមព្រៀងលើចំណុចវិវាទចំនួន ៣ចំណុច គឺចំណុចវិវាទទី២, ៤ និងទី៦។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាចំណុចវិវាទដែលនៅសល់ចំនួន ៣ចំណុច គឺចំណុចវិវាទទី១, ៣ និងទី៥។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី៧ ខែសីហា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ផ្តល់ឯកសារ និងថ្ងៃទី១០ ខែសីហា ឆ្នាំ២០២០ ជាថ្ងៃផុតកំណត់ជំទាស់ឯកសារ។

ភាគីទាំងពីរឯកភាពពន្យារកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាល ពីថ្ងៃទី២៥ ខែសីហា ឆ្នាំ ២០២០ ទៅយ៉ាងយូរ ត្រឹមថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២០ វិញ។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិរបស់លោក យុង វាសនា( YUNG VEASNA ) ជានាយកក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី០៤ ខែសីហា ឆ្នាំ២០២០ គោរពជូន ប្រធាននាយកដ្ឋានវិវាទការងារ ស្តីពីសំណើសុំផ្ទេរសិទ្ធិជូន លោក គង់ សម្បត្តិ។

២- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន លេខ MOC-៩០៩៣២៧០១ ពណ.ចបព ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០១៤។

៣- បទបញ្ជាផ្ទៃក្នុងក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន បានចុះបញ្ជីកាលេខ ០៦១ កប/អក/អធក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០១៤ ដោយប្រធាននាយកដ្ឋានអធិការកិច្ចការងារ។

៤- លក្ខន្តិកៈក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន បានតម្កល់ទុកលេខ ០០០០៥៨៤៥ ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៨ នៅការិយាល័យចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖

១- បញ្ជីរាយនាមកម្មករ-កម្មការនី កិច្ចសន្យាមានកំណត់។

២- បញ្ជីរាយនាមកម្មករ-កម្មការនី កិច្ចសន្យាគ្មានកំណត់។

៣- ប័ណ្ណសមាជិក ប.ស.ស ឈ្មោះ កួន សុខជា , ខុន ស្រីនាង , ជិន ពៅ , វឿន សាវន។

គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន លេខ ៧៤៦ ក.ប/អក/វក ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០២០។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន លេខ ០២៧/២០ កប/អក/វក/កវក២ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ របស់នាយកដ្ឋានវិវាទការងារ។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតលេខ ២៨៩ កប/អក/វក/លកអ. ចុះថ្ងៃអង្គារ ៨កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០២០ របស់លេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ជម្រាបមក លោកនាយកក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា)ហ្គាមេន ស្តីពីការជ្រើសរើសអាជ្ញាកណ្តាល។

២- កំណត់ហេតុស្តីពីការចាប់ឆ្នោតជ្រើសរើសអាជ្ញាកណ្តាលពីបញ្ជីឈ្មោះអាជ្ញាកណ្តាល ស្នើដោយសមាគមនិយោជក ចុះថ្ងៃពុធ ៩កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២០២០។

៣- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២៩១ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១០កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០។

៤- លិខិតអញ្ជើញភាគីកម្មករនិយោជិត ចូលរួមសវនាការ លេខ ២៩២ កប/អក/វក/លកអ. ចុះថ្ងៃព្រហស្បតិ៍ ១០កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤ ត្រូវនឹងថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២០។

**អង្គហេតុ**

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុននេះមានសកម្មភាពចម្បង ផ្នែកកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ២១០នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន)*
- លិខិតផ្ទេរសិទ្ធិតំណាងរបស់កម្មករនិយោជិត នៃក្រុមហ៊ុន អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ មានកម្មករនិយោជិតដែលជាដើមបណ្តឹងសរុបចំនួន ៤៦នាក់ បានផ្តិតមេដៃទាមទារ និងផ្ទេរសិទ្ធិឱ្យកម្មករនិយោជិតចំនួន ១២នាក់ មានឈ្មោះ ៖ ១. ប៉ែន ចាន់ណារី, ២. ហែម សេរីសោភា, ៣. ខុន ស្រីនាង, ៤. ស៊ាន រតណា, ៥. សេង គឹមហាន, ៦. រឿន សាវន, ៧. ជិន ស្រីពៅ, ៨. រឿន វ៉េត, ៩. សឿន សុខ ចាន់, ១០. ចាំង ចាន់មករា, ១១. លឹម ប៉ារី និង ១២. គួន សុជា ធ្វើជាអ្នកតំណាងក្នុងការដោះស្រាយវិវាទការងារនេះ។
- នាយកដ្ឋានវិវាទការងារ បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួមលេខ ០២៧/២០ ក.ប/អក/វក/ករក២ ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០ ដែលមានកម្មករនិយោជិតចំនួន ៦នាក់ មានឈ្មោះ៖ ១. ហែម សេរីសោភា ២. ខុន ស្រីនាង ៣. រឿន វ៉េត ៤. ស៊ាន រតណា ៥. ប៉ែន ចាន់ណារី ៦. សេង គឹមហាន។
- នៅថ្ងៃកំណត់ដាក់ឯកសារភស្តុតាង ភាគីកម្មករនិយោជិតបានដាក់បញ្ជីឈ្មោះបញ្ជាក់កម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចវិវាទទី១ និងទី៣ សរុបចំនួន ៣២នាក់ ក្នុងនោះរួមមានកម្មករនិយោជិតមានកិច្ចសន្យាការងារមានកំណត់ថិរវេលា ចំនួន ១៨នាក់ និងកម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ចំនួន ១៤នាក់។

ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនៅសល់

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនិយោជកមិនបានបើកជូននៅខែកុម្ភៈ ឆ្នាំ២០២០ ដូចការអនុវត្តកន្លងមក។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - និយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ តាមប្រភេទកិច្ចសន្យាការងាររបស់កម្មករនិយោជិត ដូចខាងក្រោម ៖
        - មួយឆ្នាំម្តង ឱ្យកម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។
        - ប្រាំមួយខែម្តង ឱ្យកម្មករនិយោជិតដែលមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ទោះបីជានិយោជកបន្ត ឬមិនបន្តកិច្ចសន្យាការងារក៏ដោយ។
    - និយោជកមិនទាន់បានបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត ដែលត្រូវបើកឱ្យនៅខែកុម្ភៈ ឆ្នាំ២០២០ នៅឡើយ។
    - ក្នុងចំណោមកម្មករនិយោជិតដែលទាមទារទាំងអស់ គឺកំពុងមានទំនាក់ទំនងការងារជាមួយនឹងនិយោជកនៅឡើយ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - នៅក្នុងខែកុម្ភៈ និងខែមីនា ឆ្នាំ២០២០ និយោជកមានការងារឱ្យកម្មករនិយោជិតធ្វើពេញ តែនិយោជកមិនបានបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ជូនកម្មករនិយោជិតនោះទេ ហើយនិយោជកក៏មិនបានកំណត់ពេលវេលាជាក់លាក់សម្រាប់បើកជូនវិញនោះដែរ។
    - ច្បាប់ស្តីពីការងារ មិនបានកំណត់ឱ្យនិយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំជូនកម្មករនិយោជិតទេ តែនិយោជកបានអនុវត្តកន្លងមក។ ហេតុនេះ និយោជកត្រូវអនុវត្តបន្តទៀត។
    - កម្មករនិយោជិតដែលទាមទារមានចំនួនជាង ៤០នាក់ ដោយកម្មករនិយោជិតនឹងដាក់បញ្ជីឈ្មោះបញ្ជាក់អ្នកទាមទារ។
- ភាគីនិយោជកបញ្ជាក់ថា ៖
    - និយោជកនឹងបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ជូនកម្មករនិយោជិតនៅពេលមានអ្នកបញ្ជាទិញឡើងវិញ ព្រោះឥលូវនេះ និយោជកមិនមានលទ្ធភាពបើកជូននោះទេ សុំជំពាក់សិន និងមិនអាចសន្យាថា ពេលណាអាចបើកឱ្យបាននោះទេ ដោយសារគ្មានការបញ្ជាទិញ។
    - និយោជកព្យាយាមស្វែងរកឥវ៉ាន់ឱ្យកម្មករនិយោជិតធ្វើ ដែលយ៉ាងហោចណាស់អាចបើកប្រាក់ឈ្នួលគោលឱ្យកម្មករនិយោជិតបាន ហើយច្រើនជាងប្រាក់ឧបត្ថម្ភដែលបានមកពីការព្យួរកិច្ចសន្យាការងារ។
    - រោងចក្របានព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិត ហើយទើបបើកដំណើរការវិញនៅខែកក្កដា ឆ្នាំ២០២០។ ម្យ៉ាងទៀត រោងចក្រមិនទាន់មានឥវ៉ាន់គ្រប់គ្រាន់ឱ្យកម្មករនិយោជិតធ្វើនៅឡើយ ដោយកម្មករនិយោជិតខ្លះធ្វើការតែ ២ ទៅ ៣ ថ្ងៃ ប៉ុណ្ណោះ ក្នុងមួយសប្តាហ៍។

ចំណុចវិវាទទី ៣ ៖ កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនផ្តល់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ដែលក្រុមហ៊ុនមិនបានផ្តល់ជូនកម្មករនិយោជិត

- កម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ដែលនិយោជកមិនទាន់បើកឱ្យនៅខែកុម្ភៈ ឆ្នាំ២០២០ ជូនពួកគាត់។
- ភាគីទាំងពីរទទួលស្គាល់ថា៖
  - និយោជកមិនទាន់បានបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ៥ភាគរយ ឱ្យកម្មករនិយោជិត ដែលត្រូវបើកនៅខែកុម្ភៈ ឆ្នាំ២០២០ នៅឡើយទេ។
  - ពេលវេលានៃការបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ឱ្យកម្មករនិយោជិត គឺដូចគ្នានឹងការបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ និងតាមប្រភេទនៃកិច្ចសន្យាការងាររបស់កម្មករនិយោជិត។
  - ក្នុងចំណោមកម្មករនិយោជិតដែលទាមទារទាំងអស់ គឺកំពុងមានទំនាក់ទំនងការងារជាមួយនឹងនិយោជកនៅឡើយ។
  - មូលហេតុនៃការទាមទាររបស់កម្មករនិយោជិត និងការបញ្ជាក់របស់និយោជក គឺដូចគ្នានៅក្នុងចំណុចវិវាទទី១។

ចំណុចវិវាទទី ៥ ៖ កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបង់ប្រាក់ភាគទានជូនបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ឱ្យបានទៀងទាត់ ដើម្បីឱ្យកម្មករនិយោជិតអាចប្រើសេវា ប.ស.ស. តាមមន្ទីរពេទ្យដែលជាដៃគូរបស់ ប.ស.ស. បាន

- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឱ្យនិយោជកបង់ប្រាក់ភាគទានជូនបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ឱ្យបានទៀងទាត់។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
  - កម្មករនិយោជិតមានកាត ប.ស.ស រួចហើយ តែនិយោជកមិនបានបង់ប្រាក់វិភាគទានជូន ប.ស.ស. ចាប់តាំងពីខែមករា ឆ្នាំ២០២០ មក។
  - កម្មករនិយោជិតអាចប្រើសេវា ប.ស.ស វិញបាន នៅពេលនិយោជកបង់រំលឹកប្រាក់វិភាគទានជូន ប.ស.ស. ដែលមិនទាន់បានបង់។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
  - កម្មករនិយោជិតស្ត្រីដែលបានសម្រាលកូនរួច មិនអាចទទួលបានប្រាក់បំណាច់មាតុភាព ៧០ ភាគរយ ពី ប.ស.ស. នោះទេ ព្រោះពេលពួកគាត់ទៅជួបមន្ត្រី ប.ស.ស. ដើម្បីបើកប្រាក់បំណាច់នេះ មន្ត្រី ប.ស.ស. បានប្រាប់ថា និយោជកមិនបានបង់ភាគទានជូន ប.ស.ស. នោះទេ ហើយប្រាប់កម្មករនិយោជិតឱ្យទៅជួបនិយោជកវិញ ប៉ុន្តែរដ្ឋបាលក្រុមហ៊ុនប្រាប់ឱ្យទៅទាក់ទង ប.ស.ស. វិញ។
  - ពេលកម្មករនិយោជិតទៅមន្ទីរពេទ្យដែលជាដៃគូរបស់ ប.ស.ស. ពួកគាត់មិនអាចប្រើកាតប.ស.ស. របស់ពួកគាត់ ដើម្បីទូទាត់ថ្លៃសេវាពេទ្យបាននោះទេ ចាប់តាំងពីខែឧសភា ឆ្នាំ២០២០ មក។
  - កម្មករនិយោជិតបាម្តេពេលមានគ្រោះថ្នាក់ការងារ កម្មករនិយោជិតមិនអាចប្រើសេវា ប.ស.ស. បាននោះទេ។

- និយោជកមិនបានធ្វើលិខិតបញ្ជាក់ជូនកម្មករនិយោជិត ដើម្បីស្នើឱ្យ ប.ស.ស. បង់ថ្លៃសេវាមន្ទីរពេទ្យជូនកម្មករនិយោជិតនោះទេ។

- ភាគីនិយោជកបញ្ជាក់ថា ៖
  - រោងចក្រមិនមានអ្នកបញ្ជាទិញ ធ្វើឱ្យនិយោជកជួបវិបត្តិសេដ្ឋកិច្ច និងមិនអាចបង់ប្រាក់ភាគទានជូន ប.ស.ស. បាន ហើយនិយោជកបានដាក់ពាក្យស្នើសុំពន្យារការបង់ប្រាក់ភាគទាននេះ ចាប់ពីខែមករា ដល់ខែមេសា ឆ្នាំ២០២០។ នៅខែឧសភា ឆ្នាំ២០២០ និយោជកមិនបានដាក់ពាក្យស្នើសុំពន្យារការបង់ប្រាក់ភាគទានជូន ប.ស.ស. នោះទេ ហើយក៏មិនទាន់បានបង់រំលឹកប្រាក់ភាគទានដែលបានសុំពន្យាពីមុនដែរ។
  - និយោជកបានជួបជាមួយមន្ត្រី ប.ស.ស. ដើម្បីស្នើសុំបង់រំលឹកប្រាក់ភាគទានដែលមិនទាន់បានបង់សម្រាប់កម្មករនិយោជិតស្ត្រីដែលសម្រាលកូនរួច តែមន្ត្រី ប.ស.ស. មិនទទួលយកនោះទេ ព្រោះខុសនីតិវិធីដែលតម្រូវឱ្យនិយោជកបង់ភាគទានសម្រាប់កម្មករនិយោជិតទាំងអស់។
  - ចំពោះកម្មករនិយោជិតដែលមានជំងឺធម្មតាអាចយកលិខិតបញ្ជាក់ពីនិយោជកបាន ពេលទៅមន្ទីរពេទ្យដៃគូរបស់ ប.ស.ស. សម្រាប់ការទូទាត់ថ្លៃសេវា។
  - មន្ត្រី ប.ស.ស. នឹងចុះមកត្រួតពិនិត្យរោងចក្រនៅខែសីហា ឆ្នាំ២០២០នេះ ហើយនិងធ្វើការសងសំណងដល់កម្មករនិយោជិត ព្រោះមន្ត្រី ប.ស.ស. បានចុះមកត្រួតពិនិត្យសាខារោងចក្រផ្សេងរបស់និយោជកម្តងរួចហើយ។

## ហេតុផលនៃសេចក្តីសម្រេច ៖

**អំពីភាគីដើមបណ្តឹង ៖**

នៅថ្ងៃសវនាការ ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិតដែលទាមទារចំណុចវិវាទទី១ និងទី៣នេះ មានចំនួនជាង ៤០ នាក់ ដោយកម្មករនិយោជិតនឹងដាក់បញ្ជីឈ្មោះបញ្ជាក់ពីចំនួនកម្មករនិយោជិតដែលទាមទារ។ យោងតាមបញ្ជីឈ្មោះបញ្ជាក់ពីចំនួនកម្មករនិយោជិតដែលទាមទារក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញមានកម្មករនិយោជិតចំនួន សរុប ៣២ នាក់។ ក្រោយពីបានពិនិត្យ និងផ្ទៀងផ្ទាត់ជាមួយនឹងស្នាមមេដៃរបស់កម្មករនិយោជិតទាមទារនៅក្នុងពាក្យបណ្តឹងដើម, បញ្ជីឈ្មោះបញ្ជាក់ពីចំនួនកម្មករនិយោជិតដែលទាមទារនៅក្នុងចំណុចវិវាទនេះ និងបញ្ជីវត្តមានរបស់កម្មករនិយោជិតនៅក្នុងសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្នុងចំណោមកម្មករនិយោជិតចំនួន ៣២ នាក់ ខាងលើ មានកម្មករនិយោជិតចំនួន ១ នាក់ ឈ្មោះ ប៉ុត ដាណេ អត្តលេខ H 371 មានឈ្មោះស្ទួន និងកម្មករនិយោជិតឈ្មោះ ឆាន ចំរើន អត្តលេខ ៣៣០ មិនមានឈ្មោះនៅក្នុងពាក្យបណ្តឹងដើម និងមិនមាននៅក្នុងបញ្ជីវត្តមាននៅថ្ងៃសវនាការនោះទេ។ ហេតុនេះ ចំនួនកម្មករនិយោជិតដែលទាមទារ គឺមានកម្មករនិយោជិតតែ ៣០នាក់ ប៉ុណ្ណោះ។ ( *សូមមើលបញ្ជីឈ្មោះនៅក្នុងឧបសម្ព័ន្ធ* )

**ចំណុចវិវាទទី ១ ៖ កម្មករនិយោជិតទាមទារ ឱ្យនិយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនិយោជកមិនទាន់បានបើកជូននៅខែកុម្ភៈ ឆ្នាំ២០២០ ដូចការអនុវត្តកន្លងមក**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំជូនកម្មករនិយោជិត ដូចការអនុវត្តកន្លងមកដែរឬទេ?

THE ARBITRATION COUNCIL

កថាខណ្ឌទី២ មាត្រា ១៦៧ នៃច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"ក្នុងករណីដែលមានផ្ដាច់ ឬចប់កិច្ចសន្យាមុន ដែលកម្មករនិយោជិតបានទទួលសិទ្ធិឈប់សំរាកនោះ ត្រូវសងប្រាក់បំណាច់ទៅកម្មករនិយោជិតនោះតាមកំរិតកំណត់ក្នុងមាត្រា ១៦៦ ខាងលើ"*។

កថាខណ្ឌទី៣ មាត្រា ១៦៧ ចែងថា ៖ *"ក្រៅពីករណីនេះ អនុសញ្ញារួមណាដែលមានគ្រោងឱ្យប្រាក់បំណាច់ ដោយទូទាត់សំរាប់ជួសការឈប់សំរាកព្រមទាំងការព្រមព្រៀងដែលស្ដីពីការបោះបង់ ឬមិនព្រមប្រើសិទ្ធិឈប់សំរាកប្រចាំឆ្នាំ ត្រូវទុកជាមោឃៈ ហើយគ្មានហេតុផលអ្វីទាំងអស់"*។

ផ្អែកលើខ្លឹមសារមាត្រា ១៦៧ នៃច្បាប់ស្ដីពីការងារ ការបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅសល់ ជូនកម្មករនិយោជិត អាចធ្វើទៅបានតែនៅពេលដែលមានការបញ្ចប់ ឬកាត់ផ្ដាច់ទំនាក់ទំនងការងាររបស់កម្មករនិយោជិត និងនិយោជកតែប៉ុណ្ណោះ។ មិនតែប៉ុណ្ណោះ ច្បាប់ស្ដីពីការងារបានហាមឃាត់មិនឱ្យមានការផ្ដល់ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំទេ ក្នុងអំឡុងពេលដែលនិយោជក និងកម្មករនិយោជិតនៅតែបន្តមានទំនាក់ទំនងគតិយុត្តិជាកិច្ចសន្យាការងារជាមួយគ្នានៅឡើយ។

នៅក្នុងសំណុំរឿងមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ៖ *"ចំពោះការទាមទារឱ្យក្រុមហ៊ុនទូទាត់ប្រាក់បំណាច់ជួសការឈប់សំរាកប្រចាំឆ្នាំ គឺជាការទាមទារផ្ទុយនឹងស្មារតីនៃមាត្រា ១៦៧ កថាខណ្ឌទី៣ នៃច្បាប់ស្ដីពីការងារឆ្នាំ១៩៩៧។ ដូច្នេះ ការទាមទារនេះ មិនសមហេតុសមផល និងមិនត្រឹមត្រូវឡើយ។" (សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ៩៤/០៤-អ៊ុធីណិធី ហេតុផលនៃចំណុចវិវាទទី២, លេខ ៤៥/០៥-ប៊ីអែន អិន ហេតុផលនៃចំណុចវិវាទទី១, លេខ ៨៨/១២-មែកណោតជ៍ ហ្វិតវែរ ហេតុផលនៃចំណុចវិវាទទី៦ និងលេខ ៧៣/១៣-យ៉ាក ជីន ហេតុផលនៃចំណុចវិវាទទី៨)*

កថាខណ្ឌទី១ មាត្រា ១៣ នៃច្បាប់ស្ដីពីការងារ ឆ្នាំ១៩៩៧ ចែងថា ៖ *"បទប្បញ្ញត្តិទាំងឡាយនៃច្បាប់ការងារនេះ មានលក្ខណៈជាសេចក្ដីបង្គាប់ជាសាធារណៈ វៀរលែងតែមានបដិប្បញ្ញត្តិបញ្ជាក់ច្បាស់។ ដូច្នេះវិធានទាំងអស់ដែលកើតឡើងដោយការសំរេចចិត្តជាឯកតោភាគីក្ដី ដោយកិច្ចសន្យា ឬអនុសញ្ញាណាមួយក្ដី ដែលមិនគោរពបទប្បញ្ញត្តិទាំងឡាយនៃច្បាប់នេះ ឬដែលមិនគោរពអត្ថបទទាំងឡាយដែលណែនាំអនុវត្តច្បាប់នេះ ត្រូវទុកជាមោឃៈភាពដោយច្បាប់។"*។

យោងតាមកថាខណ្ឌទី១ មាត្រា ១៣ នៃច្បាប់ស្ដីពីការងារ ខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការអនុវត្តកិច្ចសន្យាការងារ ឬការព្រមព្រៀងទាំងឡាយណាដែលផ្ទុយពីច្បាប់ស្ដីពីការងារ ឬមិនគោរពអត្ថបទទាំងឡាយដែលណែនាំអនុវត្តច្បាប់នេះ នឹងត្រូវទុកជាមោឃៈដោយពេញច្បាប់។ *(សូមមើលសេចក្ដីបង្គាប់អាជ្ញាកណ្ដាលលេខ ០០៩/១៩-តឹក ហ៊ុក (ខេមបូឌា) ហ្គាមេន)*

ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាលនៅក្នុងសំណុំរឿងខាងលើដែរ។

យោងតាមមាត្រា ១៦៧ និងមាត្រា ១៣ ខាងលើ និងអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា កិច្ចសន្យាការងាររបស់កម្មករនិយោជិតដែលទាមទារនៅក្នុងសំណុំរឿងនេះ គឺមិនទាន់បានបញ្ចប់នៅឡើយ ប៉ុន្តែការអនុវត្តកន្លងមក និយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំឱ្យកម្មករនិយោជិត។ ក្នុងករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា ការទូទាត់ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំឱ្យកម្មករនិយោជិតដែលកិច្ចសន្យាការងារមិនទាន់បានបញ្ចប់ គឺផ្ទុយពីបទបញ្ញត្តិនៃមាត្រាខាងលើ ដោយសារការទូទាត់ប្រាក់បំណាច់ជួសការឈប់សម្រាកប្រចាំឆ្នាំ ធ្វើឡើងក្នុងករណីដែលកិច្ចសន្យាការងាររបស់កម្មករនិយោជិត

ត្រូវបានបញ្ចប់តែប៉ុណ្ណោះ។ ម្យ៉ាងវិញទៀត ការអនុវត្តកន្លងមករបស់និយោជកដែលផ្តល់ប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំដល់កម្មករនិយោជិតដែលមិនទាន់បញ្ចប់កិច្ចសន្យាកាងារ គឺត្រូវទុកជាមោឃៈព្រោះផ្ទុយពីច្បាប់ស្តីពីការងារ។ ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចត្រូវបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំជូនកម្មករនិយោជិតដែលកិច្ចសន្យាការងារមិនទាន់បានបញ្ចប់ ឱ្យដូចការអនុវត្តកន្លងមកនោះទេ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិតឱ្យនិយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនិយោជកមិនទាន់បានបើកជូននៅខែកុម្ភៈ ឆ្នាំ២០២០ ដូចការអនុវត្តកន្លងមក។

**ចំណុចវិវាទទី ៣ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយដែលនិយោជកមិនទាន់បើកឱ្យនៅខែកុម្ភៈ ឆ្នាំ២០២០ ជូនពួកគាត់**

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាថា តើនិយោជកមានកាតព្វកិច្ចបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ដែលនិយោជកមិនទាន់បានបើកឱ្យនៅខែកុម្ភៈ ឆ្នាំ២០២០ ជូនកម្មករនិយោជិត ដែរឬទេ?

កថាខណ្ឌទី៦ មាត្រា ៧៣ នៃច្បាប់ស្តីពីការងារ ចែងថា ៖ *"នៅពេលបញ្ចប់កិច្ចសន្យា និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវប្រាក់បំណាច់បញ្ចប់កិច្ចសន្យានោះ ដែលសមាមាត្រនឹងប្រាក់ឈ្នួលផង សមាមាត្រនឹងចិរវេលានៃកិច្ចសន្យាការងារផង ហើយដែលចំនួនប្រាក់បំណាច់នេះមានកំណត់ក្នុងអនុសញ្ញារួម។ បើគ្មានកំណត់ក្នុងអនុសញ្ញារួមទេ ប្រាក់បំណាច់នេះយ៉ាងតិចត្រូវស្មើប្រាំភាគរយនៃប្រាក់ឈ្នួលដែលកម្មករនិយោជិតបានបើកនៅក្នុងរយៈពេលនៃកិច្ចសន្យា"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ បានបកស្រាយថា កាតព្វកិច្ចនៃការបង់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារដែលមានកំណត់ចិរវេលាដែលនិយោជកត្រូវបង់ គឺនៅពេលដែលកិច្ចសន្យាការងារដែលមានកំណត់ចិរវេលាត្រូវបានបញ្ចប់ ហើយទំនាក់ទំនងការងាររវាងនិយោជក និងកម្មករនិយោជិតត្រូវបានកាត់ផ្តាច់។ (*សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៦០/០៦-ញូមេក ហ្គាមេន ហេតុផលនៃចំណុចវិវាទទី៦, លេខ ៩៩/០៦-សៅធ៍ បាយ ហេតុផលនៃចំណុចវិវាទទី៦, លេខ ៨៥/០៩-ណាន់ គ័ង ហេតុផលនៃចំណុចវិវាទទី៤, លេខ ១២៤/០៩-ហ្វូគីស ហ្វូតវៀ ហេតុផលនៃចំណុចវិវាទទី៣, លេខ ១០៥/១១-ហ្គោលហ្វេម ហេតុផលចំណុចវិវាទទី២ និងលេខ ១៣១/១៥-សេនជ័រ វើលដ៍ ហ្គាម៉ិន ហេតុផលចំណុចវិវាទទី១)*

(ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញា-កណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

តាមអង្គហេតុដែលភាគីទទួលស្គាល់ កន្លងមកនិយោជកបានបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារចំនួន ៥ភាគរយ ជូនកម្មករនិយោជិតទាំងអស់ បើទោះបីជាពួកគាត់មានប្រភេទកិច្ចសន្យាការងារអ្វីក៏ដោយ។ ចំពោះកម្មករនិយោជិតដែលមានកិច្ចសន្យាការងារមានចិរវេលាមិនកំណត់ និយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារមួយឆ្នាំម្តងជូនពួកគាត់ ហើយសម្រាប់កម្មករនិយោជិតដែលមានកិច្ចសន្យាការងារដែលមានកំណត់ចិរវេលា និយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារនេះ នៅពេលកិច្ចសន្យាការងាររបស់ពួកគាត់ដល់កាលកំណត់ប្រាំមួយខែម្តង។ នៅក្នុងសវនាការ ភាគីទាំងពីរក៏បានបញ្ជាក់ទៀតថា កម្មករនិយោជិត គឺកំពុងមានទំនាក់ទំនងការងារជាមួយនឹងនិយោជកនៅឡើយ។

យោងតាមមាត្រា ៧៣ និងអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា និយោជកមានកាតព្វកិច្ចត្រូវទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ឱ្យកម្មករនិយោជិតដែលមានកិច្ចសន្យាការងារដែលមានកំណត់ថិរវេលា នៅពេលដែលនិយោជកបញ្ចប់កិច្ចសន្យាការងាររបស់កម្មករនិយោជិតតែប៉ុណ្ណោះ។ យ៉ាងណាមិញ ករណីនេះ ក្នុងចំណោមកម្មករនិយោជិតដែលទាមទារឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ដូចការអនុវត្តកន្លងមក គឺមិនមានកម្មករនិយោជិតណាត្រូវបាននិយោជកបញ្ចប់កិច្ចសន្យាការងារនោះទេ។ ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមិនមានកាតព្វកិច្ចត្រូវទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ជូនកម្មករនិយោជិតកំពុងមានទំនាក់ទំនងការងារជាមួយនឹងនិយោជកនោះទេ។

ជាសរុប ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ដែលនិយោជកមិនទាន់បានបើកឱ្យនៅខែកុម្ភៈ ឆ្នាំ២០២០ ជូនកម្មករនិយោជិត។

**ចំណុចវិវាទទី ៥ ៖ កម្មករនិយោជិតទាមទារឱ្យនិយោជកបង់ប្រាក់ភាគទានជូនបេឡាជាតិរបបសន្តិសុខសង្គម ប.ស.ស. ឱ្យបានទៀងទាត់**

មុននឹងពិចារណាលើការទាមទារនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាជាមុនសិនថា តើក្រុមប្រឹក្សា-អាជ្ញាកណ្តាលមានយុត្តាធិការដោះស្រាយវិវាទនេះដែរ ឬទេ?

មាត្រា ៩១ នៃច្បាប់ស្តីពីរបបសន្តិសុខសង្គម ឆ្នាំ២០១៩ ចែងថា ៖ *"វិវាទឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមរវាងសមាជិក ប.ស.ស. និយោជក និង ប.ស.ស. ត្រូវដោះស្រាយដោយគណៈកម្មការដោះស្រាយវិវាទនៃ ប.ស.ស.។ ក្នុងករណីមិនមានការសះជាវិវាទឬបណ្តឹងនោះអាចត្រូវបានប្តឹងទៅនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការងារ មុននឹងប្តឹងទៅសាលាដំបូងនៃរាជធានី ខេត្ត"*។

ផ្អែកលើខ្លឹមសារនៃមាត្រា ៩១ ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា វិវាទ ឬបណ្តឹងដែលទាក់ទងនឹងការអនុវត្តបទប្បញ្ញត្តិនានានៃរបបសន្តិសុខសង្គមរវាងសមាជិក ប.ស.ស. និយោជក និង ប.ស.ស. គឺស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង ប.ស.ស. ហើយប្រសិនបើមិនអាចដោះស្រាយបានដោយគណៈកម្មការនេះ វិវាទ ឬបណ្តឹង ប.ស.ស. ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការ មុននឹងប្តឹងទៅដល់តុលាការ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ៤៤/១៧-ហួយវណ្ណដា គ្រេនស្ព័ត អិចប្រេស ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី២ និងលេខ ០៤២/២០-យ៉ាំង ដុង ១ ខូអិលធីឌី ហេតុផលនៃចំណុចវិវាទទី១និងទី៣)*

នៅក្នុងសំណុំរឿងនេះ ភាគីកម្មករនិយោជិត គឺជាភាគីដើមបណ្តឹង ដែលបានប្តឹងទាមទារឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ពីព្រោះ និយោជកមិនបានបង់ប្រាក់ភាគទានជូន ប.ស.ស.។ បើទោះបីជាវិវាទនេះ ជាវិវាទរវាងកម្មករនិយោជិត និងនិយោជកក្តី ប៉ុន្តែផ្អែកលើខ្លឹមសារនៃមាត្រា ៩១ ខាងលើ ការដែលនិយោជកខកខានមិនបានបង់ប្រាក់ភាគទានចូល ប.ស.ស. បង្ហាញថា វិវាទនេះ ជាវិវាទរវាង ប.ស.ស. និងនិយោជក ដែលស្ថិតនៅក្រោមសមត្ថកិច្ចរបស់គណៈកម្មការដោះស្រាយវិវាទ ឬបណ្តឹង នៃប.ស.ស. ជាស្ថាប័នទទួលបន្ទុក។ ក្នុងករណីដែលវិវាទ មិនអាចដោះស្រាយបានដោយគណៈកម្មការដោះស្រាយវិវាទនេះទេ វិវាទនេះនឹងត្រូវដោះស្រាយបន្តដោយនិយ័តករសន្តិសុខសង្គម ដែលសមាជិក ប.ស.ស. កំពុងធ្វើការ មុននឹងប្តឹងទៅ

តុលាការ។ ហេតុដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា ក្រុមប្រឹក្សាអាជ្ញាកណ្តាលមិនមានយុត្តាធិការដោះស្រាយវិវាទទាក់ទងនឹងការមិនអនុវត្តបទប្បញ្ញត្តិនៃច្បាប់ស្តីពីរបបសន្តិសុខសង្គមនោះឡើយ។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

# សម្រេច និងបង្គាប់

**ចំណុចវិវាទទី ១ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់បំណាច់ទូទាត់ជួសការឈប់សម្រាកប្រចាំឆ្នាំ ដែលនិយោជកមិនទាន់បានបើកជូននៅខែកុម្ភៈ ឆ្នាំ២០២០ ដូចការអនុវត្តកន្លងមក។

**ចំណុចវិវាទទី ៣ ៖**

- បដិសេធការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបើកប្រាក់បំណាច់បញ្ចប់កិច្ចសន្យាការងារ ៥ភាគរយ ដែលនិយោជកមិនទាន់បានបើកឱ្យនៅខែកុម្ភៈ ឆ្នាំ២០២០ ជូនកម្មករនិយោជិត។

**ចំណុចវិវាទទី ៥ ៖**

- បដិសេធពិចារណាការទាមទាររបស់ភាគីកម្មករនិយោជិត ឱ្យនិយោជកបង់ប្រាក់ភាគទានជូន ប.ស.ស. ឱ្យបានទៀងទាត់។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

## ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖

ឈ្មោះ ៖ **អ៊ុំ សុទ្ធី**

ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លៈ**

ហត្ថលេខា ៖ ------------------------------

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## បញ្ជីរាយនាមកម្មករ- កម្មការនីកិច្ចសន្យាមានកំណត់

យើងខ្ញុំទាំងអស់គ្នាជាកម្មករ - កម្មការនី បម្រើការងារនៅក្នុងរោងចក្រ អេស អ៊ី ភី អាយ អេ (ខេមបូឌា) ហ្គាមេន ដែលមានទីតាំងភូមិ ត្រពាំងជ្រៃ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ល.រ | នាម-គោត្តនាម | ភេទ | អត្តលេខ | ថ្ងៃ ខែ ចូលបម្រើការងារ |
|---|---|---|---|---|
| ១ | ទ្រី បូផា | ស | 1221 | |
| ២ | ជឿន ណាជឿន | ស | 193 | 01-01-2020 |
| ៣ | យ៉ាត ពៅ | ស | 1503 | 12-04-2015 |
| ៤ | អ៊ិល ស្រីទូច | ស | B119 | 01—11- 2018 |
| ៥ | សួន សុខចន្ទ | ប | 875 | 22- 12 - 2018 |
| ~~៦~~ | ~~ឆាន ចំរើន~~ | ~~ស~~ | ~~330~~ | ~~27—05- 2019~~ |
| ៧ | ពុធ សុភក្ត្រ | ប | 332 | 12—06- 2019 |
| ៨ | សេន ណាលីន | ស | I 962 | 26—06- 2019 |
| ៩ | បាន ឡាយ | ប | I 971 | 26—06- 2019 |
| ១០ | ប៊ុត ដាណេ | ស | H 371 | 01—07- 2018 |
| ១១ | យ៉ាវ កញ្ញា | ស | CUT 874 | 01—07- 2018 |
| ~~១២~~ | ~~ប៊ុត ដាណេ~~ | ~~ស~~ | ~~H 371~~ | ~~18—01- 2019~~ |
| ១៣ | រ៉ា បូរ៉ា | ប | I 499 | 18—05- 2015 |
| ១៤ | គ្រួច ស៊ីលាង | ស | 1298 | 02—12- 2019 |
| ១៥ | ចាំង ចាន់មករា | ស | 042 | 01—09- 2018 |
| ១៦ | ឈាន ផល្លា | ស | A 385 | 01—07- 2014 |
| ១៧ | ភួន សុផា | ស | 322 | 22—12- 2018 |
| ១៨ | មួន ស្រីពៅ | ស | IS 1126 | 22—06- 2018 |

THE ARBITRATION COUNCIL

9 ខែ 8 ឆ្នាំ 2020

13 ម៉ោង 58

EE

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# បញ្ជីរាយនាមកម្មករ- កម្មការនីកិច្ចសន្យាគ្មានកំណត់

យើងខ្ញុំទាំងអស់គ្នាជាកម្មករ - កម្មការនី បម្រើការងារនៅក្នុងរោងចក្រ ធអស អ៊ី ភី អាយ ធអ (ខេមបូឌា) ហ្គាមេន ដែលមានទីតាំងភូមិ ត្រពាំងជ្រៃ សង្កាត់កាកាបទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។

| ល.រ | នាម-គោត្តនាម | ភេទ | អត្តលេខ | ថ្ងៃ ខែ ចូលបម្រើការងារ |
|---|---|---|---|---|
| ១ | ខុម សុខអយ | ស | A 385 | 01-07-2014 |
| ២ | ឯម គន្ធា | ស | A 028 | 19-06-2013 |
| ៣ | ឈិត ភារម្យ | ស | 077 | 24-06-2013 |
| ៤ | អ៊ុង ផាន់នី | ស | 597 | 16—04- 2014 |
| ៥ | សួន សាម៉ន | ស | B 159 | 15- 07 - 2014 |
| ៦ | ឆាន សុនី | ប | C 161 | 19—10- 2012 |
| ៧ | នួន វិចិត្រ | ប | B 189 | 09—01- 2011 |
| ៨ | សួន ម៉ាឡៃ | ស | 170 | 26—06- 2019 |
| ៩ | ហែម សោភា | ស | 015 | 14—11- 2011 |
| ១០ | នួន សុខខេង | ស | B 109 | 17—06- 2014 |
| ១១ | គង់ ជា | ស | CUT 874 | 01—07- 2018 |
| ១២ | ជឿន សាវន | ស | H 401 | 20—04- 2013 |
| ១៣ | វ៉ាន់ ថន | ស | 193 | 10—01- 2012 |
| ១៤ | សេង គឹមហាន | ប | BT 746 | 20—06- 2012 |

THE ARBITRATION COUNCIL